# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៥០

នាសប្តាហ៍នេះ កិច្ចដំណើរការនីតិវិធីសវនាការត្រូវបានពន្យារពេលម្តងហើយម្តងទៀត ដោយសារតែសាក្សីលោក **សុះ កំរី** ដែលជាប្រធាននៃគណៈដឹកនាំជាន់ខ្ពស់នៃកិច្ចការសាសនាឥស្លាម បានធ្វើការបដិសេធផ្ទួនៗគ្នាដោយមិនចូលរួមផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ នៅពេលព្រឹកថ្ងៃចន្ទ និងថ្ងៃអង្គារ លោកប្រធានអង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា សាក្សីរូបនេះបានបដិសេធចូលរួមសវនាការ ហើយបានបញ្ជាឲ្យមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីនាំខ្លួនសាក្សីរូបនេះមកកាន់សវនាការ ទោះបីជាប្រឆាំងនឹងចេតនារបស់សាក្សីនេះក៏ដោយ។ ឯកសារជាច្រើនជាបន្តបន្ទាប់ ត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័ររបស់តុលាការ ដោយបានបង្ហាញថា សាក្សីរូបនេះបានបដិសេធបង្ហាញខ្លួននៅចំពោះមុខតុលាការ ចាប់តាំងពីខែកញ្ញា ឆ្នាំ២០១៥ កន្លងមកម្ល៉េះ។[1] នៅទីបំផុត សាក្សីលោក **សុះ កំរី** បានមកផ្តល់សក្ខីកម្មនៅថ្ងៃពុធ ទី៦ ខែមេសា នេះ ពាក់ព័ន្ធនឹងប្រធានបទនានា រួមមាន៖ ការប្រព្រឹត្តមកលើជនជាតិចាម ការបោសសម្អាត និងមូលហេតុដែលនាំឲ្យគាត់មានចេតនាបដិសេធបង្ហាញខ្លួនក្នុងសវនាការនេះ។ មេធាវីការពារក្តីឲ្យជនជាប់ចោទលោក **នួន ជា** បានធ្វើការជំទាស់ទៅនឹងការសម្រេចចិត្តរបស់សាក្សីរូបនេះ ក្នុងការធ្វើសម្បថដោយពុំស្របតាមសាសនាឥស្លាមរបស់

---

[1] អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពី "សំណើសុំរបាយការណ៍ទាក់ទងនឹងសាក្សី 2-TCW-827"(ចុះថ្ងៃទី៥ ខែមេសា ២០១៦) E202/208/3។

ខ្លួន មុនពេលដែលឡើងផ្តល់សក្ខីកម្ម ហើយបានលើកឡើងម្តងហើយម្តងទៀតថា សក្ខីកម្មរបស់សាក្សីរូបនេះត្រូវតែចាត់ទុកថាជា “ភស្តុតាងដែលទទួលបានដោយពុំបានឆ្លងកាត់ការធ្វើសម្បថ”។ នៅថ្ងៃព្រហស្បតិ៍ លោក **ផាន វ៉ាន** បានបង្ហាញខ្លួនតាមរយៈប្រព័ន្ធសោតទស្សន៍ ដែលជាសាក្សីចុងក្រោយផ្តល់សក្ខីកម្មទាក់ទងនឹងមន្ទីរសន្តិសុខភ្នំក្រោល។ លោក **ផាន វ៉ាន** គឺជាកូនប្រុសបង្កើតរបស់អតីតលេខាតំបន់១០៥ ឈ្មោះ **តា ហាំ** ដែលមានរហស្សនាមថា **ឡាំង** ហើយគាត់ក៏ធ្លាប់បានផ្តល់សក្ខីកម្មកាលពីពេលមុននៅឆ្នាំ២០១២ ក្នុងសំណុំរឿង០០២ វគ្គ១ ផងដែរ។[2]

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ហេង ស៊ីនវុត្ថា, ម៉ាលេនី ហៃដ៍ (Melanie Hyde), នីកូឡាស មេយខក (Nicholas Maycock), ខេតលីន កាហ្វព្រៀ (Caitlin McCaffrie), នំ វិសុទ្ធ និង តាយ លីណា ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូរណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (THE WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

---

[2] សម្រាប់សេចក្តីសង្ខេបស្តីពីសក្ខីកម្មរបស់លោក **ផាន វ៉ាន** កាលពីពេលមុនក្នុងសំណុំរឿង០០២ វគ្គ១ *សូមមើល* របាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម លេខ៤៦ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៤១ (ចុះថ្ងៃទី១១ ដល់ទី១៤ ធ្នូ ឆ្នាំ២០១២) ទំព័រ ២ដល់៦។